# ពិធីស្រង់ទឹកព្រះឡូ

ពិធីនេះប្រព្រឹត្តទៅនៅថ្ងៃទី ៣ យ៉ាងឱឡារិក គឺឧបាសក ឧបាសិកា ចាស់ក្មេង ត្រូវរៀបចំបិទបាំងកន្លែងណាមួយឱ្យបានសមរម្យ ហើយយកទឹកដែលខ្លួន បានសម្រិតសម្រាំងនោះយកទៅតម្កល់ទុកនៅទីនោះហើយ ។ បន្ទាប់មកក៏នាំគ្នាចូលទៅសុំខមាទោស នឹងព្រះសង្ឃគ្រប់រូបដោយវាចាថា : យើងខ្ញុំព្រះករុណាទាំងឡាយ សូមខមាទោសនឹងព្រះសង្ឃគ្រប់រូប សូមព្រះសង្ឃគ្រប់រូបទ្រង់មេត្តាអត់នូវទោសកំហុសទាំងឡាយដែលខ្ញុំព្រះករុណាបានប្រព្រឹត្តកន្លងមក ទោះទោសកំហុសនោះបានកើតមានឡើងដោយកាយក្តី-វាចាក្តី-ចិត្តក្តី ។រួចហើយនិមន្តព្រះ សង្ឃគ្រប់រូបទៅស្រង់ទឹកពេលនោះត្រូវមានសំពត់សាដកទុកសម្រាប់ប្រគេនព្រះសង្ឃគ្រប់រូប ដើម្បីផ្លាស់ស្រង់ទឹកពេលស្រង់ព្រះសង្ឃស្រង់ដោយអង្គឯងក៏បាន ឧបាសក ឧបាសិកា បុរស ស្ត្រី យកផ្តិលដងស្រោចក៏បាន ។ ហើយតាំងសច្ចាធិដ្ឋានថា : ដោយអំណាចនៃការជ្រះថ្លានេះ សូមឱ្យកំចាត់បង់នូវឧបទ្រពចង្រៃកាឡកិណីគ្រប់យ៉ាង ហើយសូមឱ្យសិរីសួស្តី សេចក្តីសុខចំរើនគ្រប់ប្រការកើតមានដល់យើងខ្ញុំទាំងឡាយ ។